**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៧-០៩-២០០៩-អវតក/កសចស |
| ដាក់ទៅ | : | សហចៅក្រមស៊ើបអង្កេត |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Mar-2013, 15:13
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស: សម្ងាត់បំផុត/Strictly Confidential

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: **ប្តូរទៅជាសាធារណៈ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការដាក់សេចក្តីសន្និដ្ឋាន

---

**អ្នកដាក់ឯកសារ:**
ការិ.សហព្រះរាជអាជ្ញា:
លោក Andrew CAYLEY

**ចម្លងជូន:**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
ការិ.សហចៅក្រមស៊ើបអង្កេត:
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Mark B. HARMON

**ចម្លងជូន:**
ផ្នែកគាំពារការការពារក្តី:
លោក Isaac ENDELEY

**ជនសង្ស័យ:**
មាស មុត

**សហមេធាវីចាត់តាំងសម្រាប់ជនសង្ស័យ:**
លោក អាង ឧត្តម
លោក Michael G.KARNAVAS

## សំណើ

១. នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ លោក អាង ឧត្តម និង លោក Michael KARNAVAS (“សហមេធាវីចាត់តាំង”) បានដាក់ចម្លើយតបរបស់ខ្លួន (“ចម្លើយតប”)[1] ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ(“សំណើ”)[2] ដើម្បីច្រានចោលការចាត់តាំងពួកគាត់ ជាតំណាងឲ្យជនសង្ស័យ មាស មុត ក្នុងសំណុំរឿង ០០៣ តាមមូលដ្ឋាននៃទំនាស់ដែលមិនអាចផ្សះផ្សារបាន និងបុរេនិច្ឆ័យដែលមិនអាចថយក្រោយបានចំពោះរដ្ឋបាលតុលាការ។ ក្នុងសេចក្តីសម្រេច និងដីកាសម្រេចកំណត់កាលបរិច្ឆេទថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតបានអញ្ជើញសហមេធាវីចាត់តាំង ឲ្យបង្ហាញនូវការលះបង់សិទ្ធិដែលទទួលបានពីជនសង្ស័យ និងជនជាប់ចោទ អៀង សារី ក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ឲ្យធ្វើសេចក្តីសន្និដ្ឋានក្នុងរយៈពេល១០ ថ្ងៃនៃថ្ងៃធ្វើការ និងបានអញ្ជើញសហព្រះរាជអាជ្ញាឲ្យឆ្លើយតបក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ[3]។

២. ក្នុងដីកាសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការជាថ្មីឡើងវិញ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមសើបអង្កេតអន្តរជាតិ បានកត់សម្គាល់ឃើញថា “ការខ្វះការ អនុវត្តតាម”[4] របស់សហមេធាវីការពារក្តីដែលត្រូវបានចាត់តាំងរួច ទៅតាមរយៈពេលកំណត់នៅក្នុងសេចក្តីសម្រេច និងដីកាសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការ ហើយថែមទាំងបានអូសបន្លាយពេលនៃកាលបរិច្ឆេទកំណត់នៃការដាក់ឯកសាររហូតដល់ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣។ ទោះបីជាចម្លើយតបត្រូវបានដាក់ទាន់ពេលកំណត់នៅថ្ងៃទី៤ខែមីនា ឆ្នាំ២០១៣ ក៏ដោយក៏ការជូនដំណឹងត្រូវបានផ្តល់មកសហព្រះរាជអាជ្ញា នៅថ្ងៃទីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ដែរ។ តាមរយៈកំណត់ពេលនៃសេចក្តីសម្រេច និងដីកាកំណត់កាលបរិច្ឆេទចម្លើយតបណាមួយត្រូវដល់ពេលកំណត់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៣។

៣. អៀង សារី ដែលត្រូវបានតំណាងដោយសហមេធាវីការពារក្តីដែលបានចាត់តាំង នៅក្នុងសំណុំរឿងលេខ ០០២ បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣។ រឿងនេះបានបង្កើតបានជាការប្រែប្រួលមួយនៅក្នុងកាលៈទេសៈ ដែលអាចនឹងមានការទាក់ទងដល់ការវាយតម្លៃរបស់

---

[1] **D56/4/1**សំណើសុំការអនុញ្ញាតបន្ថែមចំនួនទំព័រកំណត់និងដាក់សារណារបស់សហមេធាវីស្តីពីទំនាស់ផលប្រយោជន៍ ជាសក្តានុពលក្នុងការធ្វើតំណាងលោក មាស មុត ក្នុងសំណុំរឿង ០០៣, ៤ មីនា ២០១៣។

[2] **D56/1** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យច្រានចោលការតែងតាំងសហមេធាវីចាត់តាំង ផ្អែកលើមូលដ្ឋាននៃជំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន, ២៤ ធ្នូ ២០១២។

[3] **D56/3** សេចក្តីសម្រេចនិងដីកាសម្រេចកំណត់កាលបរិច្ឆេទពាក់ព័ន្ធនឹងសំណើសុំតែងតាំងសហមេធាវីចាត់តាំង, ១១ កុម្ភៈ ឆ្នាំ២០១៣។

[4] **D56/4** ដីកាកំណត់កាលបរិច្ឆេទឡើងវិញទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានតែងតាំង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣។

សហចៅក្រមស៊ើបអង្កេត ទៅលើហានិភ័យ ដែលធ្វើជាមេធាវីការពារក្តីពីរក្នុងសំណុំរឿងដែលមាន អៀង សារី និងជនសង្ស័យ មាស មុត អាចនឹងបណ្តាលឲ្យមានជាទំនាស់ផលប្រយោជន៍ ឬបើពុំដូច្នោះទេ អាចឲ្យមានជាការបាត់បង់ប្រយោជន៍ដោយមិនអាចត្រឡប់បាននៃការគ្រប់គ្រងលើវិស័យយុត្តិធម៌។ ចំពោះមូលហេតុទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមស្នើដោយគោរពដល់ សហចៅក្រមស៊ើបអង្កេតសូមឲ្យចេញកំណត់កាលបរិច្ឆេទជាថ្មីឡើងវិញ ដើម្បីអនុញ្ញាតឲ្យ៖ (១) សហព្រះរាជអាជ្ញាមានរយៈពេលសមស្របក្នុងការដាក់ជូននូវសំណើមួយដែលបានពិនិត្យជាថ្មី, (២) សហមេធាវីការពារក្តីដែលបានចាត់តាំងអាចដាក់ចម្លើយតប, និង(៣) សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតប។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |